# ការអប់រំជាកិច្ចការទាំងអស់គ្នា

**ប៉ាន់ សំណាង** មន្ត្រីនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ
វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម
នៃរាជបណ្ឌិត្យសភាកម្ពុជា

## ១.សេចក្តីផ្តើម

*ការអប់រំ ជាឆ្អឹងខ្នងនៃការអភិវឌ្ឍជាតិ។ វិទ្យាសាស្ត្រមានការរីកចម្រើនយ៉ាងណាក៏ដោយ ក៏មិនអាចខ្វះបាននូវការអប់រំដែរ។*

*កម្ពុជាជាប្រទេសមួយមានវឿនវប្បធម៌ ដ៏ចំណាស់មួយនៅដែនដីអាស៊ីអាគ្នេយ៍ ហើយក៏ធ្លាប់ជាអរិយប្រទេស ជាពិសេសសម័យអង្គរដ៏រុងរឿង។ កម្ពុជាបច្ចុប្បន្នបាន និងកំពុងឈានដល់ដំណាក់កាលថ្មីមួយទៀតនៃការអភិវឌ្ឍ វិស័យអប់រំ ឆ្លើយតបនឹងបរិបទតំបន់ និងសកលលោក។ មិនតែប៉ុណ្ណោះ កម្ពុជាក៏មានមហិច្ឆតា និងវិសាលភាពធំទូលាយជាងមុន សំដៅលើកកម្ពស់គុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិត ក្នុងក្របខណ្ឌទូលំទូលាយ គ្របដណ្តប់លើ គ្រប់ប្រភេទ និងកម្រិតនៃការអប់រំ ជាពិសេស ស្របនឹងទស្សនវិស័យអភិវឌ្ឍន៍កម្ពុជា។*

*វាចង់បង្ហាញថា ជាការរួមចំណែកជាមួយនឹងវិស័យនានាប្រែក្លាយកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ សមិទ្ធផលអប់រំ និងឧត្តមានុវត្តន៍ជាច្រើនដែលកម្ពុជាទទួលបានពីការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងផែនការអប់រំសម្រាប់ទាំងអស់គ្នា គឺជាមូលដ្ឋាន ដ៏សំខាន់ ដើម្បីឈានទៅសម្រេចការអប់រំក្នុងបរិបទឆ្នាំ២០៣០ ខាងមុខ។[1] វិស័យអប់រំមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យមានចំណេះដឹង និងសមត្ថភាពខ្ពស់ ភាពច្នៃប្រឌិត ស្មារតីសហគ្រិនភាព នវានុវត្តន៍ និងក្រមសីលធម៌ខ្ពស់*

---

[1] *ក្រសួងអប់រំ យុវជន និងកីឡា ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជា ឆ្នាំ២០៣០គោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាពទី៤ ឆ្នាំ២០០៩*

ដើម្បីរួមចំណែក លើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្ម ដែលជួយបង្កើនកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្នតាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងលើកកម្ពស់ផលិតភាព។

ក្នុងន័យនេះ ការអប់រំជាការងារយើងទាំងអស់គ្នាដែលផ្ដោតលើការសិក្សា ការរៀន ការបង្រៀនដោយលៃយ៉ាងណាផ្ដល់នូវសេវាអប់រំប្រកបដោយគុណភាពនិងផលិតភាព។ ផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្ដីពីការអប់រំ នៅកម្ពុជារៀបចំឡើងដោយមានការពិគ្រោះយោបល់ និងការវិភាគយ៉ាងល្អិតល្អន់រវាងក្រសួង-ស្ថាប័ន អ្នកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ដើម្បីធានាបាននូវភាពប្រទាក់ក្រឡាគ្នាទៅនឹងគោលនយោបាយមានស្រាប់ដែលធ្វើឱ្យផែនទីបង្ហាញផ្លូវនេះ មានចក្ខុវិស័យ គោលនយោបាយ និងយុទ្ធសាស្ត្រប្រកបដោយភាពប្រាកដប្រជាមានសង្គតិភាពក្នុងការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពស្ដីពីការអប់រំឆ្នាំ ២០៣០ ខាងមុខ។

ក្រសួងអប់រំក៏ដូចជាស្ថាប័នពាក់ព័ន្ធ បានខិតខំរៀបចំផែនការអប់រំ គោលនយោបាយអប់រំដែលមានលក្ខណៈប្រាកដប្រជា ច្បាស់លាស់ តែក្រៅពីនេះ គ្រួសារ សហគមន៍ និងបុគ្គលម្នាក់ៗក៏ត្រូវមានគោលការណ៍អប់រំផ្ទាល់ខ្លួនផងដែរ ដើម្បីអភិវឌ្ឍន៍បញ្ញាញាណឆ្ពោះទៅកាន់គោលដៅអភិវឌ្ឍន៍រួមគ្នាដូចពាក្យមួយឃ្លាលើកឡើងថា «ការអប់រំដើម្បីទាំងអស់គ្នា ទាំងអស់គ្នាដើម្បីការអប់រំ»[2]។



**គំនរសៀវភៅ៖** រូបភាពដកស្រង់ចេញពីបណ្ដាញសង្គមហ្វេសប៊ុក

## ២.ទស្សនៈទូទៅអំពីការអប់រំ

### ២-១.និយមន័យ

តាមវចនានុក្រមសម្ដេចសង្ឃរាជ **ជួន ណាត** បានផ្ដល់ន័យពាក្យ «អប់រំ» ថាជា «ហាត់ចិត្ត; បង្វឹកចិត្ត; ដួសដុលចំពោះវិជ្ជាឬកិរិយាមារយាទ, ហ្វឹកហាត់ឲ្យស្ទាត់ជំនាញជាងមុន, កែឲ្យបានល្អប្រពៃជាងមុនជា

[2] Education For All (EFA)

លំដាប់; ខំប្រឹងបំពេញឧបនិស្ស័យឲ្យបរិបូណ៌, ខំកសាងសន្សំបុណ្យកុសលរក្សាទុកពុំឲ្យមានហ្មង, មិនឲ្យមានថ្នាំងថ្នាក់; បន្ទុំបារមី, ព្រះបរមពោធិសត្វបានអប់រំបន្ទុំបារមីអស់កាលយូរអង្វែង។ បើយោងតាមវចនានុក្រមបរទេសមួយបានបញ្ជាក់ថា «ការអប់រំជាដំណើរការនៃការទទួលឬផ្ដល់ជូននូវការបង្រៀនឬការណែនាំជាប្រព័ន្ធ ជាពិសេសនៅសាលារៀនឬសាកលវិទ្យាល័យ»។ តាមវចនានុក្រម ***Cambridge Dictionary*** ពន្យល់ថា៖ «ដំណើរការនៃការបង្រៀន ឬ ការសិក្សាជាពិសេស នៅក្នុងសាលា ឬ មហាវិទ្យាល័យ ឬ ចំណេះដឹង ដែលយើងទទួលបាន»។[3]

ការអប់រំមានន័យថា ការសិក្សាដើម្បីទទួលបានចំណេះដឹងនិងការយល់ដឹងកាន់តែស៊ីជម្រៅលើមុខវិជ្ជាផ្សេងៗដែលត្រូវយកមកអនុវត្តក្នុងជីវិតប្រចាំថ្ងៃ។ ការអប់រំមិនត្រូវបានកំណត់ចំពោះតែចំណេះដឹងពីសៀវភៅប៉ុណ្ណោះទេ ប៉ុន្តែវាក៏អាចទទួលបានតាមរយៈបទពិសោធន៍ជាក់ស្ដែងនៅខាងក្រៅថ្នាក់រៀនផងដែរ។ ក្រៅពីនេះក៏មានការលើកឡើងបន្ថែមទៀតថា ការអប់រំគឺកិច្ចដំណើរការអភិវឌ្ឍការសិក្សាឬការបណ្ដុះបណ្ដាលកាយសម្បទា សតិបញ្ញា និង សីលធម៌តាមរយៈគ្រប់សកម្មភាពអប់រំ ការធ្វើឲ្យអ្នកសិក្សាទទួលបាននូវសំណុំចំណេះដឹង ជំនាញ សមត្ថភាពនិងតម្លៃ។ ការធ្វើឲ្យមនុស្សក្លាយជាបុគ្គលល្អដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ សមាគម ប្រទេសជាតិ និងពិភពលោកទាំងមូល។[4]

ជាការពិតណាស់ ការអប់រំគឺជាសកម្មភាព ដែលមានគោលបំណងសំដៅដល់ការសម្រេចបាននូវគោលបំណងមួយចំនួន ដូចជាការបញ្ជូនចំណេះដឹង ឬការជំរុញជំនាញ និងចរិតលក្ខណៈ។ គោលបំណងទាំងនេះអាចរួមបញ្ចូលការអភិវឌ្ឍន៍ការយល់ដឹង សនិទានភាព សេចក្ដីសប្បុរស និងភាពស្មោះត្រង់។ ទ្រឹស្ដីខ្លះ តម្រូវឱ្យការអប់រំនាំឱ្យសិស្សមានភាពប្រសើរឡើង ខណៈពេលដែលអ្នកផ្សេងទៀតចូលចិត្តនិយមន័យអព្យាក្រឹតតម្លៃនៃពាក្យ។ ក្នុងន័យខុសគ្នាបន្តិច ការអប់រំក៏អាចសំដៅទៅលើដំណើរការនេះ មិនមែនសំដៅទៅលើផលិតផលនៃដំណើរការនេះទេ៖ ស្ថានភាព

---

[3] The process of teaching or learning, especially in a school or college, or the knowledge that you get from.

[4] ការឆ្លើយតបសំណួរដែលថា តើអ្វីជាការអប់រំ?ចុះផ្សាយក្នុងគេហទំព័រKhsearch.com

ផ្លូវចិត្ត និងអាកប្បកិរិយាមនុស្សដែលមាន ការអប់រំ។



ពាក្យស្លោកអប់រំ៖ តាមរបងវិទ្យាល័យហ៊ុនសែនសេរីភាព ក្រុងតាខ្មៅ ខេត្តកណ្ដាល

## ២-២.ប្រវត្តិនៃការអប់រំ

### ២.២.១-ប្រវត្តិនៃការអប់រំសកល៖

ក្នុងសៀវភៅដែលមានចំណងជើងថា« ការអប់រំនៅក្នុងប្រវត្តិសាស្ត្រពិភពលោក» របស់លោកម៉ាក ស ចនសាន់(Mark S.Johnson) និង លោក ភីតធី អិន(Peter N.) បានបង្ហាញពីរបៀបដែលជាចរន្តទូលំទូលាយនៅក្នុងប្រវត្តិសាស្ត្រឆ្លងដែនដោយផ្សារភ្ជាប់នឹងនិន្នាការនៅក្នុងស្ថាប័នអប់រំ និងការអនុវត្តការបង្រៀនតាមពេលវេលា។ ចាប់ពីសម័យបុរាណ និងសង្គមបុរាណរហូតដល់បច្ចុប្បន្ន សៀវភៅនេះបង្ហាញពីវិធីដែលការផ្លាស់ប្ដូរក្នុងជីវិតខាងសាសនា និងបញ្ញា និងគំរូសេដ្ឋកិច្ចនៅក្នុងតំបន់សំខាន់ៗនៃពិភពលោកបានបង្កើតការអភិវឌ្ឍន៍ក្នុងការអប់រំ។ ចាប់តាំងពីសម័យក្រោយបុរាណមក ទំនាក់ទំនងឆ្លងវប្បធម៌ក៏មានឥទ្ធិពលលើការផ្លាស់ប្ដូរផ្នែកអប់រំផងដែរ។[5] បើយោងតាមប្រវត្តិអប់រំចិន និងក្រិក ការអប់រំ គឺកើតតាំងពីមុនគ្រិស្តសករាជមកម្ល៉េះ។

នៅក្នុងសង្គមមុនចេះអក្សរ នេះត្រូវបានសម្រេចដោយផ្ទាល់មាត់ និងតាមរយៈការធ្វើត្រាប់តាម។ ការនិទានរឿងបានឆ្លងកាត់ចំណេះដឹង គុណតម្លៃ និងជំនាញពីមួយជំនាន់ទៅមួយជំនាន់ទៀត។



សកម្មភាពបង្រៀនៈប្រវត្តិអប់រំនៃអាមេរិក

(Image: History of The American Education System)

ខាងក្រោមនេះ ជាប្រវត្តិខ្លះនៃការអប់រំនៃប្រទេសមួយចំនួន៖

**-ប្រទេសឥណ្ឌា៖**

ការអប់រំនៅក្នុងឧបទ្វីបឥណ្ឌាបានចាប់ផ្ដើមជាមួយនឹងការបង្រៀនអំពីជាតុ

[5] https://www.routledge.com

ប្រពៃណី ដូចជា សាសនាឥណ្ឌា គណិតវិទ្យាឥណ្ឌា តក្កវិជ្ជាឥណ្ឌា ហិណ្ឌូ និងមជ្ឈមណ្ឌលពុទ្ធសាសនា ដូចជានៅ តាកសាស៊ីឡាបុរាណ (នៅប៉ាគីស្ថានសម័យទំនើប) និងណាឡាន់ដា (នៅឥណ្ឌា)។

ការអប់រំឥស្លាម បានជាប់ពាក់ព័ន្ធជាមួយនឹងការបង្កើតអាណាចក្រអ៊ីស្លាមនៅក្នុងឧបទ្វីបឥណ្ឌាក្នុងយុគសម័យកណ្តាល ខណៈដែលការមកដល់នៃពួកអឺរ៉ុប ហើយក្រោយមកបាននាំយកការអប់រំលោកខាងលិចទៅកាន់ប្រទេសឥណ្ឌាអាណានិគម។



Chanakyaជាទស្សនវិទូជាអ្នកច្បាប់ និងជាគ្រូដ៏អស្ចារ្យម្នាក់របស់ឥណ្ឌា (ស.វទី២)

សាកលវិទ្យាល័យតាមបែបបស្ចិមប្រទេស ជាច្រើនត្រូវបានបង្កើតឡើងក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់អង់គ្លេសក្នុងសតវត្សទី១៩។ ទីបំផុត វិធានការបន្តបន្ទាប់គ្នាពេញមួយពាក់កណ្តាលដើមសតវត្សទី២០ បានក្លាយជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធអប់រំនៃសាធារណរដ្ឋឥណ្ឌា ប៉ាគីស្ថាន និងភាគច្រើននៃឧបទ្វីបឥណ្ឌា។

**-ប្រទេសក្រិកៈ**

ការអប់រំសម្រាប់ប្រជាជនក្រិក ត្រូវបាន "ប្រជាធិបតេយ្យ" យ៉ាងទូលំទូលាយនៅសតវត្សទី៥មុនគ.ស. ដែលទទួលឥទ្ធិពលដោយ សុភីស ផ្លាតូ និង អ៊ីសូក្រាត។ ក្រោយមក នៅសម័យហេលែនីស្ទីក (Hellenistic)[6] នៃប្រទេសក្រិកបុរាណ ការអប់រំនៅក្នុងសាលាកាយសម្ព័ន្ធ (Gymnasium) ត្រូវបានគេចាត់ទុកថា មានសារៈ សំខាន់សម្រាប់ការចូលរួមក្នុងវប្បធម៌ក្រិក។ តម្លៃនៃការអប់រំកាយចំពោះជនជាតិក្រិក និង រ៉ូមបុរាណ មានលក្ខណៈពិសេសជាប្រវត្តិសាស្ត្រ។ ការអប់រំនៅប្រទេសក្រិកបុរាណមានពីរទម្រង់ៈ ផ្លូវការ និងក្រៅផ្លូវការ។ ការអប់រំផ្លូវការ ត្រូវ

6 ពេលដែលរីកពាលដាលនៃវប្បធម៌ក្រិកពាសពេញមេឌីទែរ៉ាណេខាងកើតនិងអាស៊ី បន្ទាប់ពីការសោយទីវង្គត់របស់អេឡិចសាន់ឌឺ(Alexander ស្តេចអេហ្ស៊ីប)

បានសម្រេចតាមរយៈការចូលរៀននៅសាលារដ្ឋ ឬត្រូវបានផ្ដល់ដោយគ្រូដែលជួល។ ការអប់រំក្រៅប្រព័ន្ធ ត្រូវបានផ្ដល់ដោយគ្រូដែលមិនមានប្រាក់ខែ ហើយបានកើតឡើងនៅក្នុងកន្លែងមិនសាធារណៈ។ ការអប់រំ គឺជាធាតុផ្សំដ៏សំខាន់នៃអត្តសញ្ញាណរបស់មនុស្ស។ ការអប់រំភាសាក្រិក ជាផ្លូវការជាចម្បងសម្រាប់បុរស និងមិនមែនជាទាសករ។ នៅក្នុងរដ្ឋប៉ូលីស(**Polis**) ភាគខ្លះ ច្បាប់ត្រូវបានអនុម័តដើម្បីហាមឃាត់ការអប់រំទាសករ។ អ្នករស់នៅស្ប៉ាតា ឬប្រជាជនស្ប៉ាតា (**Spartans**) ក៏បានបង្រៀនតន្ត្រី និងរបាំផងដែរ ប៉ុន្តែក្នុងគោលបំណងបង្កើនភាពបត់បែនរបស់ពួកគេក្នុងនាមជាទាហាន។



**Pythagoras** គឺជាទស្សនវិទូក្រិកម្នាក់ដែលគេស្គាល់ដោយសារការរួមចំណែករបស់គាត់ចំពោះគណិតវិទ្យា

**-ប្រទេសចិន៖**

នៅឆ្នាំ២០០០មុនគ.ស ការអប់រំរបស់ចិន បានរីកចម្រើនដល់កម្រិតដែលបានបង្កើតឡើងជាពិសេសនូវកន្លែងសិក្សាសម្រាប់គោលបំណងនៃការរៀនសូត្រ។ ពីឆ្នាំ៨០០ ទៅ ឆ្នាំ៤០០ មុនគ.ស. ប្រទេសចិនមានទាំង គួស្វៀរ ( Guoxue:សាលារដ្ឋាភិបាល) និងហ្សាំងស្វៀរ (Xiangxue: សាលាក្នុងស្រុក)។ ការអប់រំនៅក្នុងប្រទេសចិនបែបប្រពៃណីត្រូវបានគ្របដណ្ដប់ដោយឃូជិ (keju:ប្រព័ន្ធប្រឡងសេវាស៊ីវិល)[7] ដែលបានចាប់ផ្ដើមអភិវឌ្ឍប្រហែល ឆ្នាំ៤០០ នៃគ.សនិងកាន់តែរីកចម្រើននៅក្នុងរជ្ជកាលរាជវង្សតាំង (ឆ្នាំ៦១៨ដល់៨៩៦នៃគ.ស)។

ឃូជិ(Keju) គឺជាកម្មវិធីស្រាវជ្រាវមួយដែលផ្អែកលើគោលគំនិតខុងជឺ។ ប្រព័ន្ធប្រឡងចូលបម្រើ ការងារស៊ីវិល(Keju) នេះនៅតែជាមធ្យោបាយដាច់ខាតមួយសម្រាប់មុខតំណែងរដ្ឋាភិបាលសម្រាប់ឥស្សរជនដែលមានការអប់រំរបស់ប្រទេសចិនអស់រយៈពេលជាង១០០០ ឆ្នាំ។[8]

---

[7] civil service examination system

[8] អានបន្ថែម៖ https://education.stateuniversity.com/pages/269/China-HISTORY-BACKGROUND.html#ixzz7hXi8Mzb



***ខុងជឺ** គឺជាទស្សនវិទូ និង អ្នកនយោបាយចិនដែលជាឥស្សរជនជាន់ខ្ពស់ចិន ហើយបានផ្តល់គំនិតអប់រំល្អៗក្នុងសង្គមចិន។*[9]

## ២.២.២-ប្រវត្តិអប់រំនៃកម្ពុជា

*នៅប្រទេសកម្ពុជា ការសិក្សាកើតមានឡើងតាំងពីសម័យព្រេងនាយ។ ប៉ុន្តែ កាលពីដើមឡើយ មាននៅតែត្រកូលស្តេចប៉ុណ្ណោះ។ បុត្រាបុត្រីស្តេច មន្ត្រីតូចធំសុទ្ធតែបានទទួលការសិក្សាបរិបូរណ៍។ ដោយប្រទេសកម្ពុជាទទួលឥទ្ធិពលពុទ្ធសាសនា និងព្រាហ្មណ៍សាសនា។ ប្រទេសកម្ពុជាគោរពសាសនាទាំងពីរនេះ។ នៅសម័យហ្វូណនការសិក្សាមានការរីកចម្រើនហើយ។ ភិក្ខុសាមណេរ បានទទួល លើករហូតដល់វិជ្ជាជាន់ខ្ពស់។ កាលនោះ មានព្រះថេរអង្គខ្លះបានសិក្សាខ្ពង់ខ្ពស់ ចេះវិជ្ជាច្រើនប្រការ ។ជាពិសេសទៀតនោះ នៅសម័យអង្គរ ការសិក្សាឡើងដល់ថ្នាក់ខ្ពស់បំផុត។ មានអ្នកប្រាជ្ញច្រើននាក់ អ្នកប្រាជ្ញពុទ្ធសាសនា អ្នកប្រាជ្ញសាសនាព្រាហ្មណ៍ ខ្លះជាបុរោហិត ខ្លះជាព្រះរាជគ្រូ។ ក្នុងរាជសំណាក់មានមហាវិទ្យាល័យជាន់ខ្ពស់ សម្រាប់ព្រះរាជត្រកូលនៅក្នុងវត្តជ័យស្រីព្រះខាន់។* **ព្រះនាងឥន្ទ្រទេវី** *ជាព្រះអគ្គមហេសីនៃ***ព្រះបាទជ័យវរ្ម័នទី៧***ជាទ្រង់ជាសាកលវិទ្យាធិការ។*[10]



***រូបព្រះនាងឥន្ទ្រទេវី៖** (រូបភាពរបស់គេហទំព័រសាបាយ* news.sabay.com.kh *ចុះផ្សាយនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១)*

*ក្រោយៗមក ការសិក្សាអប់រំមានការធ្លាក់ចុះដូចជានៅសវទី១៨ និងសម័យខ្មែរ*

---

[9] *ការបង្រៀន និងទស្សនវិជ្ជារបស់ ខុងជឺ គាំទ្រវប្បធម៌ និងសង្គមអាស៊ីបូព៌ា ដែលនៅតែមានឥទ្ធិពលនៅទូទាំងប្រទេសចិន និងអាស៊ីបូព៌ារហូតមកដល់សព្វថ្ងៃនេះ។*

[10] *កង ឌិម ការអប់រំនិងការអភិវឌ្ឍនៅកម្ពុជា ទំព័រទី៤ ការផ្សាយរបស់វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ២០២០*

ក្រហមជាដើម។ អ្វីដែលយើងគួរកត់សម្គាល់គឺនៅ**ការអប់រំសម័យអាណាពីគមនិយមបារាំង** ប្រទេសកម្ពុជាមានទីតាំងស្ថិតនៅក្នុងជ្រោយឥណ្ឌូចិន ហើយបានស្ថិតនៅក្រោមរបបអាណាព្យាបាលបារាំង ចាប់ពីឆ្នាំ ១៨៦៣ ដល់ឆ្នាំ១៩៥៣។ នៅពេលមុននឹងប្រទេសបារាំងចូលមកកាន់កាប់ប្រទេសកម្ពុជាត្រូវបានទទួលរងនូវការគាបសង្កត់ពីសំណាក់ប្រទេសជិតខាងឥតឈប់ឈរ។ ទាក់ទងនឹងវិស័យអប់រំ របស់ប្រទេសកម្ពុជានាសម័យនោះ ការសិក្សាបានធ្វើឡើងនៅតាមទីវត្តអារាម ដែលជាមជ្ឈមណ្ឌលវប្បធម៌អរិយធម៌ដ៏សំខាន់របស់ខ្មែរ។ ការអប់រំតាមបែបប្រពៃណីនាពេលនោះ គឺព្រះសង្ឃបានដើរតួវតទីយ៉ាង សំខាន់ជាគ្រូបង្រៀនជាអ្នកផ្ទេរចំណេះដឹងដល់កូនខ្មែរ។

ក្រោយសម័យទាមទារឯករាជ្យបានពីអាណានិគមបារាំង ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ ១៩៥៣ វិស័យអប់រំនៅកម្ពុជាមានការរីកចម្រើនយ៉ាងខ្លាំងក្លា។ សាលារៀនកើតមាននៅគ្រប់វត្តអារាម និង ទីប្រជុំជន។ ក្នុងសម័យសង្គមរាស្ត្រនិយម ព្រះករុណាព្រះបាទនរោត្តមសីហនុ ទ្រង់សព្វព្រះទ័យក្នុងការធ្វើឲ្យវិស័យអប់រំ អភិវឌ្ឍដល់កម្រិតខ្ពស់ តាំងពីថ្នាក់បឋមសិក្សារហូតដល់ឧត្តមសិក្សា។ ទីជនបទឆ្ងាយដាច់ស្រយាលក៏មានសាលាបឋមសិក្សា និង អនុវិទ្យាល័យដែរ ហើយក្រោយពីផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុលពត ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ១៩៧៩ ប្រព័ន្ធអប់រំជាតិទាំងមូលត្រូវបានបង្កើត និង ស្តារឡើងវិញ តាមរយៈការប្រមែប្រមូលធនធានគ្រូ សិស្ស និស្សិត ដែលនៅសេសសល់ពីការកាប់សម្លាប់ ក្រោមការឧបត្ថម្ភ ជំនួយបច្ចេកទេសពីបណ្តាប្រទេសសង្គមនិយមនានា។ គ្រូបង្រៀនដែលនៅរស់រានមានជីវិតមានចំនួនតិចតួចពេក នៅពេលនោះក្រសួងអប់រំក៏អនុវត្តគោលការណ៍ «អ្នកចេះច្រើនបង្រៀនអ្នកចេះតិចអ្នកចេះតិចបង្រៀនអ្នកមិនចេះ»។ គ្រូបង្រៀនគ្មានចំណេះដឹង និងខ្វល់គ្មានកោសល្យហៅថា «គ្រូចាត់តាំង»។ គ្រូបង្រៀនដែលនៅរស់រានមានជីវិតពីរបប ប៉ុល ពត ហៅថា "គូចាស់ ក៏មានតួនាទីជាអ្នកផ្តល់ចំណេះដឹងគរុកោសល្យដល់-គ្រូចាត់តាំង»។ ដោយផ្អែកលើគោលការណ៍ ការសិកាត្រូវផ្សារភ្ជាប់នឹងជីវភាព។ ទាំងសៀវភៅសិក្សា និង កម្មវិធីសិក្សាសុទ្ធសឹងតាក់តែងនិងរៀបចំថ្មីទាំងអស់។

កំណែទម្រង់រចនាសម្ព័ន្ធនៃប្រព័ន្ធអប់រំនៅកម្ពុជា ការប្រែប្រួលផ្នែកនយោបាយ និង សង្គម-សេដ្ឋកិច្ច បានតម្រូវឱ្យមានកំណែទម្រង់ប្រព័ន្ធអប់រំជាបន្តបន្ទាប់។ នៅមុនឆ្នាំ ១៩៧៥ កម្ពុជារក្សាប្រព័ន្ធអប់រំមួយ តាមគេរ

ដំណែលរបស់បារាំង មានរយៈពេលសិក្សា ១៣ឆ្នាំ (៦+៤+២+១) និង ឆ្លងកាត់ការប្រឡងធំៗ ៤ ឬ ៥ដង។ ក្រោយឆ្នាំ១៩៧៩ ផ្អែកតាមតម្រូវការបន្ទាន់របស់ប្រទេសជាតិ ក្រសួងអប់រំបានអនុវត្តប្រព័ន្ធអប់រំ១០ឆ្នាំ (៤+៣+៣) ហើយចាប់ផ្ដើមពង្រីកឲ្យទៅជាប្រព័ន្ធ១១ឆ្នាំ (៥+៣+៣) ចាប់ពីឆ្នាំ១៩៨៦ ដល់ឆ្នាំ១៩៨៦។[11] ក្នុងបរិបទថ្មីរបស់ប្រទេសជាតិ ក្រសួងអប់រំ យុវជន និង កីឡា បានបន្តកែលម្អប្រព័ន្ធ អប់រំតម្រង់កម្មវិធីសិក្សា ពាក់តែងសៀវភៅសិក្សាថ្មី បំប៉នសមត្ថភាពជាថ្មីដល់គ្រូបង្រៀន ដើម្បីត្រៀម លក្ខណៈផ្ដើមអនុវត្តប្រព័ន្ធអប់រំ១២ឆ្នាំ (៦+៣+៣) នៅក្នុងឆ្នាំសិក្សា១៩៩៦-១៩៩៧ មកទល់បច្ចុប្បន្ន។ ប្រព័ន្ធអប់រំថ្មី បានបង្កើនម៉ោងសិក្សាសម្រាប់គ្រប់កម្រិតថ្នាក់នៃបឋមសិក្សា។ រចនាសម្ព័ន្ធនៃប្រព័ន្ធអប់រំកម្ពុជាចុងក្រោយ បានបង្កើនចំណេះដឹងសិស្សមួយកម្រិតទៀត គឺពី១១ឆ្នាំ ដល់១២ឆ្នាំ ដោយបន្ថែម១ឆ្នាំ ទៀតនៅបឋមសិក្សា។ ប្រព័ន្ធនេះ បង្ហាញពីការចូលរៀនរបស់កុមារនៅអាយុ៣ឆ្នាំនៅមត្តេយ្យសិក្សារយៈ ពេល៣ឆ្នាំគឺ កម្រិតមត្តេយ្យកម្រិតទាប មត្តេយ្យកម្រិតមធ្យម និង មត្តេយ្យកម្រិតខ្ពស់ បន្ទាប់ពីមុនពេល គេចូលរៀននៅបឋមសិក្សា ដែលមានអាយុ៦ឆ្នាំ ឬ យ៉ាងតិច៧២ខែ។ ប្រព័ន្ធនេះ ក៏មានភាពទន់ភ្លន់ផងដែរ ចំពោះសិស្សដែលបញ្ចប់អនុវិទ្យាល័យ អាចបន្តការសិក្សាទៅរកឯកទេសណាមួយ តាមមជ្ឈមណ្ឌល ឬ សាលាបច្ចេកទេស និងវិជ្ជាជីវៈសម្រាប់ឈានឆ្ពោះទៅទីផ្សារពលកម្មការងារ។

ក្រោយមក នៅដំណាក់កាលថ្មី ចាប់ពីឆ្នាំ១៩៩៧ ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជាដែលមាន**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រី** វិស័យអប់រំ មានការរីកចម្រើនយ៉ាងខ្លាំង។ សំណង់អគារសិក្សា អគារធនធាន អគារកាត់ដេរ សួនបន្លែ ឬបន្ទប់កុំព្យូទ័រ មានស្ទើរគ្រប់ទីកន្លែង ទោះបីសាលារៀននៅតំបន់ជនបទ ក៏ដូចទីក្រុងដែរ ពិសេសក្រសួងអប់រំ យុវជននិងកីឡា មានគោលនយោបាយបង្កើតវិទ្យាល័យឱ្យមានគ្រប់តាមឃុំ-សង្កាត់នៅទូទាំងប្រទេស។

[11] កង ឱម ការអប់រំនិងការអភិវឌ្ឍនៅកម្ពុជា ទំព័រទី៨ ការផ្សាយរបស់វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ២០២០



*រូបសិស្សានុសិស្សរៀនកុំព្យូទ័រ៖នៅវិទ្យាល័យពេជ្រចិន្តា ស្ថិតក្នុងភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។*



***រូបសួនបន្លែនិងសិស្សានុសិស្សប្រមូលផលបន្លែរបស់ខ្លួន៖*** *នៅវិទ្យាល័យពេជ្រចិន្តា ស្ថិតក្នុងភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។*



***រូបសិស្សានុសិស្សរៀបចំអគារកាត់ដេរ៖*** *វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នជំនីក ក្នុងស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ*



***រូបអគារធនធាន៖*** *វិទ្យាល័យហ៊ុនសែនសេរីភាព ក្នុងក្រុងតាខ្មៅ ខេត្តកណ្តាល*



***រូបអគារធនធាន៖*** *វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនអម្ពវ័នជំនីក ក្នុងស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ*

កំណែទម្រង់ប្រព័ន្ធអប់រំនៅកម្ពុជាបានទទួលផ្លែផ្កាជាច្រើន ក្នុងការអភិវឌ្ឍអប់រំ ដូចរូបភាពខាងលើបញ្ជាក់ស្រាប់ មិនថាក្នុងទីក្រុងឬជនបទចុងកាត់មាត់ញកឬតាមបន្ទាត់ព្រំដែន ក៏មានការរីកចម្រើនបានទៅដល់ដែរ។



*រូបភាពលោកគ្រូ-អ្នកគ្រូនិងថ្នាក់ដឹកនាំអប់រំៈវិទ្យាល័យ ពេជ្រចិន្តា ជា**អង្គភាពឆ្នើម**ដែលជាអតីតម្ចាស់ជ័យលាភីសម្រាប់ការប្រកួតអង្គភាពឆ្នើមរបស់ក្រសួងអប់រំ។*

### ២-៣.ទស្សនៈអ្នកអប់រំល្បីៗ៖

ការអប់រំបែបប្រពៃណីក្តី ការអប់រំទំនើបក្តី ច្រើនអនុវត្តតាមទ្រឹស្តីល្អៗនៃអ្នកប្រាជ្ញឬអ្នកអប់រំ(Educators)។ តទៅនេះយើង សូមលើកយកគោលទ្រឹស្តីរបស់អ្នកប្រាជ្ញខ្លះៗមកបង្ហាញ៖

**-ព្រះពុទ្ធ៖**( Guatama Buddha )

ព្រះពុទ្ធ គឺជាសាស្ត្រាចារ្យដ៏ជំនាញមួយរូប ហើយព្រះអង្គមានជំនឿយ៉ាងមោះមុតក្នុងអានុភាពនៃពាក្យពោលដើម្បីបញ្ចុះបញ្ចូលមនុស្ស ឲ្យផ្លាស់ប្តូរបែបបទនៃជីវិតរបស់គេ, ឲ្យគេព្រមប្រកាន់យកតម្លៃថ្មី និងស្វែងរកគោលដៅថ្មី។ នៅពេលមួយនោះ កាលដែលគ្រូប្រដៅសាសនាជាបដិបក្ខទាំងឡាយ បានពឹងផ្អែកលើមន្តអាគមនិងសកម្មភាពអច្ឆរិយៈដើម្បីបញ្ចុះបញ្ចូល ប្រមូលសាវ័កឲ្យបានច្រើនសម្រាប់ក្រុមរបស់គេ, ព្រះពុទ្ធបានប្រកាន់យកតែអច្ឆរិយភាពតែមួយប្រភេទប៉ុណ្ណោះ គឺ "អច្ឆរិយភាពនៃការប្រៀនប្រដៅ" (អនុសាសនីបាដិហារិយៈ)។

**សម្រង់សម្តីទាក់ទងការបង្រៀន៖**«មហាសមុទ្រ មានរសតែមួយ អំបិលក៏មានរសដូច្នោះដែរ ការបង្រៀន និង ច្បាប់វិន័យនេះក៏មានរសតែមួយ គឺរសនៃសេរីភាព។ ការបង្រៀនរបស់ខ្ញុំមិនមែនជាទស្សនវិជ្ជាទេ។ វាជាលទ្ធផលនៃបទពិសោធន៍ផ្ទាល់... ការបង្រៀនរបស់ខ្ញុំ គឺជាមធ្យោបាយនៃការ អនុវត្ត មិនមែនជាអ្វីដែលត្រូវតម្កល់ឬថ្វាយបង្គំទេ។ ការបង្រៀនរបស់ខ្ញុំប្រៀបដូចជាក្បូនដែលប្រើ សម្រាប់ឆ្លងទន្លេ។ គឺមានតែមនុស្សល្ងីល្ងើទេ ដែលជិះក្បូនជុំវិញ បន្ទាប់ពីគាត់បានទៅដល់ច្រាំងទន្លេពោរពេញដោយសេរីភាព»។[12]



[12] http://www.azquotes.com

ក្រៅពីទស្សនៈនេះ ព្រះអង្គក៏បានមានពុទ្ធដីកាបន្ថែមថា៖«**ការសិក្សាគឺមិនចេះចប់ពីព្រោះជីវិតក៏មិនដែលឈប់សិក្សាដែរ**»។[13]

**-លោកចាន់ណាក់យ:**( Chanakya )

ប្រហែលឆ្នាំ៣២១ មុនគ.ស. **ព្រះគ្រូចាន់ណាក់** បានជួយអធិពជ Mauryan ដំបូងបង្អស់ Chandragupta ក្នុងការឡើងកាន់អំណាច ហើយត្រូវបានគេសរសើរយ៉ាងទូលំទូលាយថាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតអាណាចក្រ Maurya។លោកជាគ្រូបង្រៀន ទស្សនវិទូ សេដ្ឋវិទូ អ្នកច្បាប់ ទីប្រឹក្សា Chandragupta Maurya ត្រូវបានគេស្គាល់ថា: តួនាទីលេចធ្លោនៅក្នុងមូលដ្ឋានគ្រឹះនៃអាណាចក្រ Maurya។

**សម្រង់សម្ដី៖** «ការអប់រំគឺជាមិត្តល្អបំផុត។ អ្នកពូកែដោយទង្វើរបស់អ្នក។ សេចក្ដីល្អរបស់បុគ្គលនោះ ផ្សាយទៅគ្រប់ទិសទី។ សៀវភៅ គឺសម្រាប់អ្នកមានប្រាជ្ញា»។

**-សាវីទ្រីប៉ៃ ភូលេ** (Savitribai Phute)

**សាវីទ្រីប៉ៃ**(Savitribai) ជាអ្នកគ្រូបង្រៀន ជាទីប្រឹក្សា និងជាម្ដាយនៃទ្រឹស្ដីស្រ្ដីនិយមរបស់ឥណ្ឌា។



សាវីទ្រីប៉ៃ ភូលេ (Savitribai Phute:1831-1887)

**សាវីទ្រីប៉ៃ**( Savitribai) តែងតែនិយាយអំពីថាតើការអប់រំមានសារៈសំខាន់យ៉ាងណា។ នាងចង់ឲ្យ មនុស្សប្រុសស្រីគ្រប់រូប មានអប់រំ និង មានសេរីភាព។ ទោះបីជាមានការប្រឆាំងពីសង្គមក៏ដោយ នាងដឹងថា ***ការអប់រំគឺជាមធ្យោបាយតែមួយគត់ដើម្បីសម្រេចបាននូវឯករាជ្យភាព*។** គំនិតដែលគួរអោយកត់សំគាល់បំផុតរបស់ **សាវីទ្រីប៉ៃ ភូលេ** (Savitribai Phule) គឺអំពីសមភាពវណ្ណៈ។ នាងមានចំណេះខ្ពង់ខ្ពស់ខ្លាំងជាងអ្នកផ្សេងៗទៀតដែលរស់នៅសម័យកាលនោះ។

**សម្រង់សម្ដី៖** «***ការអប់រំគឺជាមធ្យោបាយតែមួយគត់ដើម្បីសម្រេចបាននូវឯករាជ្យភាព***»។

[13] Never stop learning, because life never stop teaching.

-**អារីស្តូត**(Aristotle)

អារីស្តូត ជាជនជាតិក្រិចបុរាណដែលដឹងរឿងមួយចំនួនអំពីការអប់រំ ធ្លាប់បានធ្វើការសង្កេតមួយដើម្បីដាក់ចំណាត់ថ្នាក់សមាជិកមួយចំនួននៃ PTA ។



លោកបានមានប្រសាសន៍ថា "*អ្នកដែលអប់រំកូនឲ្យបានល្អ គឺ មានកិត្តិយសជាងអ្នកដែលបង្កើតវា ទៅទៀត។ សម្រាប់អ្នកទាំងនេះបានផ្តល់ជីវិតតែមួយគត់ គឺសិល្បៈនៃការរស់នៅដ៏ល្អ*។ ម្យ៉ាងវិញទៀត ឪពុកម្តាយជាអ្នកបង្កើតកូន គ្រូ ជាអ្នកប្រែក្លាយពួកគេទៅជាមនុស្ស។

-**ចន ឌីវី** (JOHN Dewey)

*លោក ចន ឌីវី*(JOHN Dewey)ជាទស្សនវិទូអាមេរិកដ៏ល្បីល្បាញម្នាក់នាសរទី២០។



លោក ចន ឌីវី (JOHN Dewey:1859-1952)

ឥទ្ធិពលរបស់ **ចន ឌីវី** លើការអប់រំត្រូវបានបង្ហាញឱ្យឃើញនៅក្នុងទ្រឹស្តីរបស់គាត់អំពីការរៀនសូត្រសង្គម។ គាត់ជឿថា **សាលាគួរតែជាតំណាងនៃបរិយាកាសសង្គម ហើយសិស្សរៀនបានល្អបំផុតនៅពេលស្ថិតនៅក្នុងសង្គមធម្មជាតិ** ។

-**អាប្រាហាម ម៉ាស្លូវ** (Abraham Maslow)

**អាប្រាហាម ម៉ាស្លូវ**( Abraham Maslow) គឺជាអ្នកចិត្តវិទ្យាអាមេរិកាំង[14]ដ៏ល្បីល្បាញនាសរទី២០។លោកបានផ្តល់ជាទស្សនៈជាច្រើនទាក់ទងការអប់រំដោយលោកបានលើកឡើងថា «តម្រូវការកាន់តែច្រើនដែលត្រូវបានបំពេញ សិស្សនឹងរៀនកាន់តែច្រើន»។ ឋានានុក្រមរបស់ Maslow ត្រូវបានបង្កើតឡើងដោយ**អាប្រាហាម ម៉ាស្លូវ**

[14] https://www.verywellmind.com

( Abraham Maslow) ក្នុងឆ្នាំ១៩៥៤ គឺជាវិធីនៃការរៀបចំតម្រូវការមូលដ្ឋានរបស់សិស្សនៅកម្រិតផ្សេងៗគ្នា[15]។




កម្រិតណាដែលឆ្លើយតបកាន់តែច្រើន សិស្សនឹងរៀនកាន់តែច្រើន។




**សម្រង់សម្ដី៖** «មនុស្សដែលសម្រេចចិត្តដោយខ្លួនឯង អ្នកដែលឈានដល់កម្រិតនៃភាពចាស់ទុំ សុខភាព និងការបំពេញដោយខ្លួនឯងមានច្រើនណាស់ក្នុងការបង្រៀនយើង ដែលពេលខ្លះហាក់ដូចជា ពូជមនុស្សខុសគ្នា»។ (Self-actualizing people, those who have come to a high level of maturation, health, and self-fulfillment, have so much to teach us that sometimes seem almost like a different breed of human beings.)

ការលើកឡើងពីសម្រង់សម្ដីខ្លះៗរបស់អ្នកអប់រំ ឬទស្សនវិទូមួយចំនួនមកខាងលើនេះ វាគ្រាន់ជាទស្សនទានដែលឆ្លុះបញ្ចាំងពីការខិតខំប្រឹងប្រែងរួមគ្នានៃមនុស្សជាតិទូទៅលើកពផែនដីនេះ។គឺអ្នកទាំងអស់នេះហើយ ជាបុព្វបុរសអប់រំដែលជួយដល់ការកែប្រែសង្គមនិងអភិវឌ្ឍគោលគំនិតនានាឆ្ពោះមកសតវត្សថ្មីនេះ។

### ៣.ការអប់រំជាការងារទាំងអស់គ្នា

មនុស្សយើងម្នាក់ៗ មិនអាចរស់នៅផ្ដាច់ចេញពីគ្នាបានទេ ហើយការប្រាស្រ័យទាក់ទងគ្នា ជាមធ្យោបាយមួយកសាងសុខដុមនីយកម្មសម្រាប់ពួកយើង។ការសិក្សា អប់រំ ជាមូលដ្ឋានចាំបាច់បំផុតក្នុងការជួយបុគ្គលម្នាក់ៗ គ្រួសារនីមួយៗ សហគមន៍មួយ ប្រទេសមួយ ក៏ដូចពិភពលោកទាំងមូលពោរពេញទៅដោយធនធានមនុស្ស ដើម្បីឆ្លើយតបនឹងការអភិវឌ្ឍប្រកបដោយចីរភាព និងនិរន្តរភាព។

[15] សូមអានបន្ថែមនៅ(McLeod, 2007)

នេះគឺជាកោសិកាសំខាន់ៗដែលត្រូវរួមគ្នាដើម្បីការអប់រំ៖

**៣-១.គ្រួសារ**

ឪពុកម្ដាយ ជាគ្រូដើម(បុព្វាចារ្យ)របស់កូនប្រុសស្រី។ ម្ដាយឪពុកឬឪពុកឬម្ដាយមានតួនាទីជាអាណាព្យាបាលលើសមាជិកដទៃក្នុងគ្រួសារ ។ ពួកគេ ជាអ្នកទទួលខុសត្រូវលើសមាជិកគ្រួសារក្នុងការផ្ដល់តម្រូវការចាំបាច់គ្រប់យ៉ាងឱ្យគ្រួសារ។ ភារកិច្ចរបស់ម្ដាយឪពុកចំពោះកូនមាន[16]៖

- ស្រឡាញ់ថ្នាក់ថ្នមនិងយោគយល់ដល់កូនទាំងអស់ស្មើៗគ្នា។
- ពង្រីកការអប់រំខាងស្មារតី សីលធម៌ វិន័យផ្ទាល់ខ្លួន និងសាសនា ។
- ត្រួតពិនិត្យរាល់សកម្មភាពនិងការកំសាន្ត។
- អប់រំកូនឱ្យឧស្សាហ៍ព្យាយាមអត់ធ្មត់ សន្សំសំចៃ និងមានជំនឿលើខ្លួនឯង ។
- ជួយជំរុញ លើកទឹកចិត្តកូនឱ្យធ្វើកិច្ចការផ្ទះ កិច្ចការសាលារៀននិងកិច្ចការសង្គម។ បង្រៀនគេពីភារកិច្ចជាពលរដ្ឋនិងធ្វើឱ្យពួកគេមានគំនិតចេះស្រឡាញ់ជាតិ ។
- ផ្ដល់ដំបូន្មានល្អៗ ចំពោះការអភិវឌ្ឍនិងសុខុមាលភាព ។
- ធ្វើជាគំរូល្អដល់ពួកគេ។ ទុកដាក់ពួកគេឱ្យមានតួស្រុកតាមប្រពៃណីនិងចែកទ្រព្យសម្បត្តិប្រសិនបើម្ដាយឪពុកមានលទ្ធភាព។



គ្រួសារមានវិន័យ កូនៗច្រើនទទួលបានការអប់រំបានល្អនិងសិក្សាបានខ្ពង់ខ្ពស់។



រូបម្ដាយបង្រៀនកូន៖ រូបភាពមន្ទីរអប់រំខេត្តកំពង់ឆ្នាំង

**៣-២.សហគមន៍-អង្គការពាក់ព័ន្ធ**

ការសិក្សាមិនមែនចេះតែជោគជ័យឬសំណាងនោះទេ ។ពាក្យ«សំណាង»ជាពាក្យកម្ចាយបានមកពីពាក្យ «សាង» ហេតុនេះដើម្បីទទួលបានភាពជោគជ័យក្នុងការ

16 ដកស្រង់ពីសៀវភៅសិក្សាសង្គម ថ្នាក់ទី៧ បោះពុម្ពដោយក្រសួងអប់រំ ទំព័រ១៩៣

សិក្សាអប់រំ លុះត្រាតែមានផែនការអប់រំបណ្តុះបណ្តាលមួយត្រឹមត្រូវ ពិសេសនោះក៏ត្រូវមានគ្រូបង្គោលឬអ្នកដឹកនាំអប់រំមានជំនាញច្បាស់លាស់។ ជាក់ស្តែងនៅកម្ពុជា យើងមានសហគមន៍ជាច្រើនចូលរួមសកម្មភាពអប់រំក្រៅពីប្រព័ន្ធអប់រំនៅសាលាសាធារណៈដោយមានសមាគមមាតាបិតាជាច្រើនៗក្រៅពីនេះ នៅក្នុងសៀវភៅមួយមានចំណងជើងថា«ប្រព័ន្ធអប់រំអាស៊ាន»[17] បានលើកឡើងពីបាវចនាអាស៊ានថា «ទស្សនវិស័យតែមួយ អត្តសញ្ញាណតែមួយ សហគមន៍តែមួយ» (One Vision, One Identity, One Community)។ តាមបាវចនាអាស៊ាននេះ មានន័យថា អាស៊ានជាសហគមន៍មួយដែលរួមគ្នា ក្នុងការអភិវឌ្ឍវិស័យអប់រំរួមគ្នា។

ទន្ទឹមនឹងនេះ យើងក៏សង្កេតឃើញមានអង្គការជាច្រើនបម្រើឱ្យវិស័យអប់រំ ទាំងអង្គការជាតិ និងអង្គការអន្តរជាតិ ដូចជាអង្គការយូនីសេហ្វ (UNICEF)[18] អង្គការទស្សនៈពិភពលោក (World Vision) អង្គការយូណេស្កូ (UNESCO) សហគមន៍សិក្សាអេហ្វ ធូ អេស[19]ជាដើម។




រូបសាលាមត្តេយ្យសហគមន៍៖ នៅស្រុកបាកាន ខេត្តពោធិសាត់

## ៣-៣.សាលារៀន

សាលារៀន ជាអង្គភាពមួយផ្តល់សេវាកម្មនៃការសិក្សា រិន័យ។សាលា ក៏ជាកន្លែងដែលក្មេងៗទៅរៀនដើម្បីទទួលបានការអប់រំ (a place where children go to be educated)[20]។ នៅលើពិភពលោកនេះ នៅប្រទេសនានា សាលាមានសាលារដ្ឋផង សាលាឯកជន ហើយប្រទេសខ្លះមានការវិវត្ត ខ្លាំងជាយូរមកហើយ ដោយគ្រាន់តែរូបភាពផ្សេងគ្នាប៉ុណ្ណោះដូចដើម្បីដឹកនាំកិច្ចខិតខំប្រឹងប្រែងឆ្លើយតប ចំពោះស្ថានភាពអាសន្ន។

---

[17] សៀវភៅប្រព័ន្ធអប់រំនៅអាស៊ាន បោះពុម្ពដោយគ្រឹះស្ថានស្រាវជ្រាវនិងបោះពុម្ពហាតប៊ុក ២០២២

[18] យូនីសេហ្វ គឺជាអង្គការមួយក្នុងចំណោមអង្គការដំបូងៗ ដែលបានវិលត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោយការដួលរលំ របបខ្មែរក្រហមក្នុងឆ្នាំ ១៩៧៩

[19] ជាសាលាឯកជនមួយដែលបម្រើសេវាអប់រំអ្នករៀនខ្សោយឱ្យរៀនប្រសើរឡើងវិញ

[20] ដកស្រង់ពីវចនានុក្រម Cambridge Dictionary តាមគេហទំព័រdictionary.cambridge.org

ជាករណីប្រទេសចិន[21] ដែលបានលើកមកខាងលើជាដើម។

នៅស.វ.ទី២១នេះ ចរន្តសកលភាវូបនីយកម្មវិស័យអប់រំមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យមានចំណេះដឹង និង សមត្ថភាពខ្ពស់ ភាពច្នៃប្រឌិត ស្មារតីសហគ្រិនភាព នវានុវត្តន៍ និងក្រមសីលធម៌ខ្ពស់ ដើម្បីរួមចំណែក លើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្ម ដែលជួយបង្កើនកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និង បរិយាបន្ន តាមរយៈការធ្វើពិពិធកម្ម សេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងលើកកម្ពស់ផលិតភាព[22]។ ដូច្នេះសាលារៀន មិនថាសាលារដ្ឋឬសាលាឯកជន ដើរតួនាទីសំខាន់ណាស់ក្នុងការរៀបចំផែនការអប់រំដែលជួយឱ្យលោកគ្រូ-អ្នកគ្រូឬអ្នកអប់រំ បញ្ជ្រាបចំណេះដឹងដល់សិស្ស-និស្សិតស្របតាមគោលនយោបាយអប់រំរបស់រដ្ឋាភិបាលដែលមានក្រសួងអប់រំយុវជន និងកីឡាជាសេនាធិការ។

## ៣-៤.ក្រសួងអប់រំ-ស្ថាប័នពាក់ព័ន្ធ

នៅតាមប្រទេសនានា ក្រសួងអប់រំរបស់ប្រទេសនោះ មានតួនាទីសំខាន់ក្នុងការអប់រំដោយគ្រប់គ្រងទាំងសាលារដ្ឋនិងសាលាឯកជន។ ជាក់ស្តែងនៅប្រទេសព្រុយណេរដ្ឋាភិបាលគ្រប់គ្រងទាំងសាលារដ្ឋនិងសាលាឯកជន។[23]

ចំពោះក្រសួងអប់រំកម្ពុជា កម្ពុជាត្រូវឆ្លងដំណាក់កាលជាច្រើនទម្រាំមកដល់ថ្ងៃនេះ។ រដ្ឋាភិបាលមានបំណងជំរុញឱ្យកម្ពុជាឡើងឋានៈជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០។ ប្រសិនបើកម្ពុជាមិនអាចដោះស្រាយបាននូវបញ្ហានានាដែលរាំងស្ទះដល់ការអភិវឌ្ឍប្រព័ន្ធអប់រំដ៏រឹងមាំនោះទេ កម្ពុជាអាចជាប់ផុងនៅក្នុងស្ថានភាពមានចំណូលកម្រិតមធ្យមតែមានកំណើនយឺត។[24] តែបើយើងពិនិត្យដោយល្អិតល្អន់ក្រសួងអប់រំមានការខិតខំប្រឹងប្រែងជាទីបំផុត ដោយរៀបចំកម្មវិធីជារៀងរាល់ឆ្នាំក្នុង

---

[21] ឆ្នាំ800 ទៅ ឆ្នាំ400 មុនគ.ស. ប្រទេសចិនមានទាំង គួស្វៀរ (Guoxue:សាលារដ្ឋាភិបាល) និងហ្យាំងស្វៀរ (Xiangxue: សាលាក្នុងស្រុក)។ ការអប់រំនៅក្នុងប្រទេសចិនបែបប្រពៃណី ត្រូវបានគ្របដណ្តប់ដោយឃូជិ (keju: ប្រព័ន្ធប្រឡងសេវាស៊ីវិល)[21] ដែលបានចាប់ផ្តើមអភិវឌ្ឍប្រហែល ឆ្នាំ400 នៃគ.សនិងកាន់តែរីកចម្រើននៅក្នុងរជ្ជកាលរាជវង្សតាំង(ឆ្នាំ៦១៨ដល់៨៩៦នៃគ.ស)។

[22] សេដ្ឋកិច្ចអាស្រ័យការអប់រំ(Economy based on Khnowledge)

[23] សៀវភៅប្រព័ន្ធអប់រំនៅអាស៊ាន បោះពុម្ពដោយគ្រឹះស្ថានស្រាវជ្រាវនិងបោះពុម្ពហាតប៊ុក ២០២២

[24] ស្រង់ពីសៀវភៅការអប់រំនៅកម្ពុជាឆ្នាំ២០១៥ បោះពុម្ពដោយវិទ្យាស្ថានបណ្តុះបណ្តាលនិងស្រាវជ្រាវដើម្បីអភិវឌ្ឍកម្ពុជា ទំព័រ១ ឆ្នាំ២០១៥

ការបម្រើឱ្យវិស័យអប់រំ ដូចជាសិក្ខាសាលាបំប៉នសមត្ថភាព ការប្រឡងជ្រើសរើសគ្រូបង្រៀន ការចុះអនុស្សារណៈជាមួយអង្គការក្រុមហ៊ុន និងប្រទេសជាដៃគូជាដើម។




*រូបភាពនៃការចុះអនុស្សារណៈ៖ ក្រសួងអប់រំ យុវជន និងកីឡា និងក្រុមហ៊ុនមិត្តហ្វូន បានចុះ**អនុស្សរណៈជាដៃគូយុទ្ធសាស្ត្រយូរអង្វែងដើម្បីសហការគ្នាលើគម្រោង "បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ក្នុងវិស័យអប់រំ" ដែលកិច្ចសហការនេះ ជាភាពជោគជ័យមួយបន្ថែមទៀតនៃកម្មវិធី "អ៊ីនធឺណែតសម្រាប់សាលារៀន" ដែលធ្លាប់បានសហការអនុវត្តនាពេលកន្លងមក។***





***រូបឯកឧត្តម ប្រាក់ កុសល** អគ្គលេខាធិការរងនៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច **ឯកឧត្តម សរ សុពុត្រា** អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ស្ពឺ និង**លោកស្រី** Staphanie Selle **ប្រធានអង្គការពិភពកុមារ និងអភិវឌ្ឍន៍៖** បានអញ្ជើញជាអធិបតីក្នុងពិធីបើកវគ្គបំប៉នស្តីពីការងារគ្រប់គ្រង ការផ្តល់សេវាទារកដ្ឋានក្នុងសហគមន៍ និងចំណេះដឹងការអភិវឌ្ឍន៍កុមារតូចដល់គណៈកម្មការប្រឹក្សាយោបល់នឹងអ្នកពាក់ព័ន្ធ ដែលប្រព្រឹត្តទៅពីថ្ងៃទី6-7 ខែកញ្ញា ឆ្នាំ2022 នៅបណ្ណាល័យខេត្តកំពង់ស្ពឺ។*

មិនតែប៉ុណ្ណោះ ក្រសួងអប់រំក៏មានកិច្ចសហប្រតិបត្តិការជាដៃគូជាមួយស្ថាប័នផ្សេងៗទៀតផងដែរ ដែលរួមគ្នាលើកកម្ពស់វិស័យអប់រំនៅកម្ពុជា។កន្លងមក នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានចេញសេចក្តីជូនដំណឹង ស្តីពីកិច្ចសហការរវាងក្រសួងអប់រ យុវជន និងកីឡា ជាមួយក្រសួងព័ត៌មាន ក្នុងការរៀបចំផលិត និងផ្សព្វផ្សាយកម្មវិធី «ការសិក្សាពីចម្ងាយ» និង «ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក»។ កម្មវិធីនេះ បានជួយច្រើនដល់សិស្ស និស្សិត

ពិសេសកុមារតូចៗក្នុងការសិក្សាពីចម្ងាយក្នុងបរិបទកូវីដ-១៩។



រដ្ឋមន្ត្រីក្រសួងអប់រំ និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

ជារួម មិនថាក្រសួងអប់រំ ឬស្ថាប័នពាក់ព័ន្ធដទៃទៀតដូចជាក្រសួងនានាដែលជាសេនាធិការរដ្ឋាភិបាលទេ ក្រុមហ៊ុនឬដៃគូរអភិវឌ្ឍសុទ្ធតែខិតខំពុះពារ ដើម្បីការអប់រំដើម្បីទាំងអស់គ្នា ដូចជាករណីថ្មីៗនេះ ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីអប់រំ បានធ្វើជាអធិបតីក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំតាមប្រព័ន្ធZoom ក្នុងគោលដៅពិនិត្យឡើងវិញអំពីការអនុវត្តអាទិភាពសកម្មភាពសំខាន់ៗនិងការបង្កើតយុទ្ធសាស្ត្រថ្មី ដើម្បីប្រើប្រាស់ធនធានឱ្យបានសមស្របសម្រាប់កែលម្អការអប់រំនៅកម្ពុជា។[25]




រូបឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីអប់រំ និង សកម្មភាពប្រជុំក្រុមការងារបច្ចេកទេសចម្រុះវិស័យ អប់រំតាមប្រព័ន្ធZoom

[25] យោងតាមការចុះផ្សាយរបស់គេហទំព័រក្រសួងអប់រំ នៅថ្ងៃទី០៩សីហា ២០២២

## សន្និដ្ឋាន

*ជាចុងបញ្ចប់ ការអប់រំសម្រាប់ទាំងអស់មានគោលបំណងជាច្រើនត្រូវបានបង្កើតឡើងដើម្បីកសាងមូលដ្ឋានគ្រឹះសម្រាប់របៀបវារៈនៃការអប់រំថ្មី។*

*តាមការលើកយកមកខាងលើ ទោះបីមានគំនិតរួមគ្នាយ៉ាងណាក៏ដោយ តែបើគ្មានឆន្ទៈក៏មិនអាចទៅរួចដែរ។អ្វីៗផ្សារភ្ជាប់គ្នាទាំងអស់ ទាំងធនធានមនុស្ស ទាំងគោលនយោបាយ ទាំងថវិកា ហើយបើយើងនិយាយពីថវិកាគឺផ្តោតលើសេដ្ឋកិច្ចនេះឯង។ ការបើកបេះដូងទទួលយករួមគ្នា ពិសេសការផ្តល់ការអប់រំដំបូងដោយឥតគិតថ្លៃ និងជាកាតព្វកិច្ច ការអភិវឌ្ឍជំនាញដែលទាក់ទងនឹងការងារ ជារឿងចាំបាច់។ នោះវាអាចជួយជំរុញភាពជាពលរដ្ឋសកលលោក និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព ការបង្កើនចំនួននៃគ្រូបង្រៀន និងគុណភាពនៃការអប់រំ ដោយមានការធានាថា រដ្ឋាភិបាលមានឆន្ទៈក្នុងការធ្វើ និងប្រកាន់ខ្ជាប់នូវការប្តេជ្ញាចិត្តផ្នែកហិរញ្ញវត្ថុចាំបាច់។ ចំណែកស្ថាប័ន ឬបុគ្គលពាក់ព័ន្ធ ត្រូវបំពេញការងារដោយសីលធម៌វិជ្ជាជីវៈខ្ពស់ ឈរលើការអភិវឌ្ឍការអប់រំរួមគ្នា។*

**ឯកសារពិគ្រោះ**

-កង ឌិម *ការអប់រំនិងការអភិវឌ្ឍនៅកម្ពុជា* ការផ្សាយរបស់វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ២០២០

-ក្រសួងអប់រំ *ផែនទីបង្ហាញផ្លូវការអប់រំកម្ពុជាឆ្នាំ២០៣០គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤* ២០១៩

-ក្រសួងអប់រំ *សិក្សាសង្គមថ្នាក់ទី៧* ២០១៩

-ក្រុមអ្នកសរសេរហោតប៊ុក *ប្រព័ន្ធអប់រំអាស៊ាន* ការផ្សាយរបស់គ្រឹះស្ថានស្រាវជ្រាវនិងបោះពុម្ពហាត ប៊ុក ២០២២

-ឃៀង សុធី ស្រ៊ីនីវ៉ាសា ម៉ាឌូ ឆែម រិទ្ធី *ការអប់រំនៅកម្ពុជាឆ្នាំ២០១៥* ការផ្សាយរបស់វិទ្យាស្ថានបណ្តុះ បណ្តាលនិងស្រាវជ្រាវ ដើម្បីអភិវឌ្ឍកម្ពុជា ២០១៥

-ជួន ណាត *វចនានុក្រមខ្មែរ* ការផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ១៩៦៧

**ប្រភពគេហទំព័រ**

-www.khsearch.om

-http://www.moeys.gov.kh

-www.cnbc.com

-https://education.stateuniversity.com

-https://www.verywellmind.com

-https://www.azquotes.com

-www.dictionary.cambridge.org

-www.thefamouspeople.com

-www.pinterest.com

- https://www.routledge.com